# តើយើងអាចរំពឹងអ្វីពីព្រះជាម្ចាស់នៅពេលនេះ ?
# សេចក្តីពិតខាងវិញ្ញាណ ទី១

កម្រងសំណេរតែងសេចក្ដីនេះ ផ្ដោតលើរបៀបដែលអ្នកជឿ អាចទុកចិត្តព្រះជាម្ចាស់ ក្នុងពេលដែលមានបញ្ហា។



*ព្រះយេស៊ូវជួបពួកសិស្សពីរនាក់ តាមផ្លូវទៅឯអេម៉ូស -- Charters Cathedral, ប្រទេសបារាំង*

តើព្រះជាម្ចាស់គង់នៅទីណា?! ហេតុអ្វីបានជាព្រះអង្គមិនធ្វើការជួយយើងឲ្យបានច្រើនជាងនេះ? តើព្រះទ្រង់មិនធ្វើអ្វីសោះឬ? ប្រសិនបើលោកអ្នកកំពុងសួរសំណួរដូចនេះ វាគឺជាសញ្ញាបង្ហាញថា អ្នកមានការយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅ អំពីអ្វីដែលកំពុងកើតឡើង ក្នុងពិភពលោកយើង នាពេលបច្ចុប្បន្ននេះ។ អ្នកជឿលើព្រះ ហើយជឿថាទ្រង់អាចជាសេចក្ដីជំនួយដ៏ធំ។ ប៉ុន្តែ អ្នកមានភាពច្របូកច្របល់ ឬមិនអស់ចិត្ត ឬក៏ចេះតែភ័យខ្លាច។ អ្នកមិនមានអារម្មណ៍ដឹងនូវព្រះវត្តមាននៃព្រះ ឬជំនួយមកពីព្រះអង្គ ឲ្យស្មើនឹងអ្វីដែលអ្នកត្រូវការ ឬរំពឹងចង់បាន ហើយអ្នកក៏ចង់បានលើសពីនោះថែមទៀត។

សំណេរតែងសេចក្ដីខ្លីខាងក្រោមនេះ គឺជាសំណេរទីមួយ ក្នុងចំណោមកម្រងតែងសេចក្ដីចំនួនប្រាំពីរ ដែលមានប្រធានបទស្ដីពី "តើយើងអាចរំពឹងអ្វីពីព្រះនៅខណៈពេលនេះ?" នេះគឺជាការប្រមូលផ្ដុំនៃសេចក្ដីពិតខាងវិញ្ញាណ ដែលមានមូលដ្ឋានគ្រឹះលើព្រះគម្ពីរ សម្រាប់អស់អ្នកដែលស្គាល់ ហើយស្រឡាញ់ និងបម្រើព្រះ ព្រមទាំងអស់អ្នកដែលដឹងពីរបៀបដែលពួកគេអាចទុកចិត្តព្រះ នៅក្នុងពេលដែលមានបញ្ហា។

**សេចក្ដីពិតខាងវិញ្ញាណ ទី១៖ ចូរចងចាំថា អ្នកមានសមត្ថភាពនៅមានកម្រិត ក្នុងការយល់ពីព្រះហឫទ័យ និងពីផ្លូវរបស់ព្រះជាម្ចាស់។ ដូច្នេះ ទទួលយកអស់ទាំងការដែលទ្រង់ប្រទានមកចុះ។** (អេសាយ ៥៥:១-៩; លូកា ២៤:១៣-២២)

ប្រសិនបើយើងពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ ពីសេចក្ដីរំពឹងដែលយើងមានចំពោះព្រះ ពួកយើងភាគច្រើននឹងរកឃើញថា យើងរំពឹងចង់ឲ្យព្រះធ្វើអ្វី ដែលស្របតាមគំនិត និងបំណងចិត្តរបស់យើង។ ប្រហែលជាការរំពឹង

បែបនោះ ត្រូវបានផ្ដួចផ្ដើមដោយសារសេចក្ដី ដែលយើងបានអាននៅក្នុងព្រះគម្ពីរ ឬការដែលបានស្ដាប់ឮគ្រូអធិប្បាយ តែបើសង្កេតឲ្យជិតដល់ទៅ គឺថា ពួកយើងភាគច្រើនប្រាថ្នា ហើយសង្ឃឹម និងរំពឹងចង់ឲ្យព្រះ ធ្វើអ្វីដែលយើងចង់ឲ្យទ្រង់ធ្វើ។ ហើយ តើមានអ្វីកើតឡើង នៅពេលដែលព្រះមិនធ្វើសម្រេចឲ្យយើង តាមការដែលយើងបានសង្ឃឹម ឬរំពឹងពីទ្រង់? យើងងាយនឹងឈឺចាប់ ភាន់ច្រឡំ អស់សង្ឃឹម ឬថែមទាំងខឹងសម្បារផង។ ដូច្នេះ សំណួរសួរថា តើគួរតែបន្ទោសព្រះ ឬក៏ជាការរំពឹងខុសរបស់យើង?

អ្នកនិពន្ធព្រះគម្ពីរប្រាប់យើងម្ដងហើយម្ដងទៀតថា យើងមិនគួរមានការភ្ញាក់ផ្អើល នៅពេលដែលព្រះមិនបំពេញតាមសេចក្ដីរំពឹងរបស់យើងនោះឡើយ។ ហេតុផលគឺសាមញ្ញ។ អ្នក និង ខ្ញុំ មិនអាចស្គាល់ ឬយល់ព្រះរាជគំនិតរបស់ព្រះ ហើយព្រះអង្គតែងតែកំពុងធ្វើការ តាមរបៀបដែលយើងមិនអាចមើលឃើញ និងអាចត្រឹមតែដឹងដោយសង្កេតមើលហេតុការណ៍ ក្រោយដែលវាបានកើតឡើងហើយប៉ុណ្ណោះ។

### *អ្វីដែលយើងត្រូវយល់*

តាមរយៈហោរាអេសាយ យ៉ាវេហ៍ (ព្រះជាអម្ចាស់) ពន្យល់ដល់ពួកថា ផ្លូវរបស់ព្រះមិនមែនជាផ្លូវរបស់យើងទេ។ លោកបានថ្លែងថា៖

ពីព្រោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា
គំនិតអញ មិនមែនដូចជាគំនិតរបស់ឯងរាល់គ្នាទេ
ឯផ្លូវរបស់ឯងរាល់គ្នាក៏មិនមែនជាផ្លូវរបស់អញដែរ។
ដ្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាងណា
នោះអស់ទាំងផ្លូវរបស់អញ ខ្ពស់ជាងផ្លូវរបស់ឯង
ហើយគំនិតរបស់អញ ក៏ខ្ពស់ជាងគំនិតរបស់ឯងរាល់គ្នាយ៉ាងនោះដែរ។
(អេសាយ ៥៥:៨-៩)

លោកអេសាយកំពុងថ្លែងថា យើងត្រូវឈប់ព្យាយាមចង់យល់ភាពស្មុគស្មាញ ឬភ្ញាក់ផ្អើលចំពោះការដែលព្រះធ្វើ (ឬមិនធ្វើ)។ ផ្ទុយទៅវិញ យើងគួរតែផ្ចង់ចិត្តលើអ្វីដែលយើងអាចយល់ និងមានប្រយោជន៍ដល់យើង។ នៅក្នុងបរិបទនេះផ្ទាល់ លោកអេសាយកំពុងបរិយាយអំពីព្រះហឫទ័យរបស់ព្រះ ក្នុងការបំពេញនូវសេចក្ដីត្រូវការជាមូលដ្ឋានខាងវិញ្ញាណរបស់ពួកគេ។ ទោះបីអ៊ីស្រាអែលទំនងជាមិនអាចចាប់បានការដែលព្រះពន្យល់ហេតុផល អំពីរបៀបដែលទ្រង់ធ្វើការនៅក្នុងពិភពលោកនេះក៏ដោយ ពួកគេនៅតែអាចទទួលបានផលប្រយោជន៍ ពីសេចក្ដីស្រឡាញ់ សេចក្ដីមេត្តា និងព្រះគុណរបស់ព្រះ ប្រសិនបើពួកគេឈោងចាប់នូវអ្វី ដែលព្រះទ្រង់កំពុងតែប្រទានមក។ ពួកគេអាចប្រែចិត្តចេញពីអំពើបាបរបស់ពួកគេ ហើយអនុញ្ញាតឲ្យព្រះបំពេញតម្រូវការដ៏ស៊ីជ្រាលជ្រៅ និងការចង់បានខាងវិញ្ញាណរបស់ពួកគេ។ លោកបានថ្លែងថា៖

ហឺយ អស់អ្នកដែលស្រេកអើយ ចូរមកឯទីទឹកចុះ
ឯអ្នកដែលគ្មានប្រាក់អើយ ចូរមកទិញ ហើយបរិភោគទៅ!
អើ ចូរមកទិញស្រាទំពាំងបាយជូរ និងទឹកដោះគោ
ឥតបង់លុយ ឥតថ្លៃទេ។

ហេតុអ្វីបានជាចាយប្រាក់ឲ្យ បានតែរបស់ដែលមិនមែនជាអាហារ
ហើយបង់កំឡាំង ឲ្យបានតែរបស់ដែលមិនស្កប់ចិត្តដូច្នេះ?
ចូរស្តាប់តាមអញឲ្យអស់ពីចិត្តចុះ នោះឯងនឹងបានបរិភោគយ៉ាងឆ្ងាញ់
ដើម្បីឲ្យព្រលឹងឯងបានស្កប់ស្កល់ ដោយម្ហូបយ៉ាងថ្លៃវិសេស។
ចូរឱនត្រចៀក ហើយមកឯអញ
ចូរស្តាប់ចុះ នោះព្រលឹងឯងនឹងបានរស់នៅ។
(អេសាយ ៥៥:១-៣)

ស្ថិតក្នុងពេលអស់សង្ឃឹម យើងប្រហែលមានការគ្របសណ្តប់ដោយភាពភ័យខ្លាច និងការប្រាថ្នាចង់បានជំនួយខ្លាំងពេក ទើបធ្វើឲ្យយើងខកខានមិនទទួលបានអ្វីដែលមានស្រាប់សម្រាប់យើង។ ដរាបណាយើងប្រកាន់ចិត្តព្យាយាមចង់បានអ្វីដែលយើងមិនអាចបាន (ដូចជា ចម្លើយទៅកាន់សំណួរដែលមិនអាចឆ្លើយបាន ការធានាសុវត្ថិភាព ការធានាបាននូវសុខភាពល្អ ការកម្សាន្តចិត្តចេញពីប្រភពខុស ឬអ្វីផ្សេងទៀតដែលសំខាន់ចំពោះយើង ប៉ុន្តែវាហួសពីការដែលយើងអាចឈោងចាប់ដល់) នោះយើងនឹងស្ថិតក្នុងភាពតប់ប្រម៉ល់ និងភាពមិនស្កប់ចិត្តរហូត។ ផ្ទុយទៅវិញ ប្រសិនបើយើងទុកមួយឡែកនូវអ្វីដែលយើងមិនអាចយល់ ហើយផ្ចង់ចិត្តលើការឈោងចាប់យកនូវអ្វីដែលមានក្នុងរង្វង់ដៃរបស់យើង នោះយើងនឹងទទួលបាននូវបទពិសោធន៍ នៃសេចក្តីសុខសាន្តដ៏អស្ចារ្យខាងក្នុងចិត្ត។ យើងនឹងមានការរៀបចំខ្លួនកាន់តែប្រសើរ ដើម្បីប្រឈមមុខនឹងបញ្ហា ហើយយើងនឹងចាប់ផ្តើមមើលឃើញកាន់តែប្រសើរ ពីរបៀបដែលព្រះកំពុងធ្វើការនៅក្នុងយើង និងតាមរយៈយើង សម្រាប់ជាការល្អ។

***សូមឲ្យព្រះយេស៊ូវបើកភ្នែករបស់អ្នក***

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងឃើញរឿងអំពីការដែលព្រះយេស៊ូវជួបនឹងសិស្សពីរនាក់ នៅតាមផ្លូវទៅឯអេម៉ូស។ រឿងចុងក្រោយដែលពួកគេបានដឹងគឺ ព្រះយេស៊ូវត្រូវគេឭជាប់លើឈើឆ្កាង ទ្រង់បានសុគត ហើយត្រូវគេបញ្ចុះនៅក្នុងផ្នូរ។ ក្តីសង្ឃឹមដ៏ច្រើន ដែលពួកគេមានសម្រាប់ជីវិតរស់នៅ និងអនាគតរបស់ពួកគេ ស្រាប់តែត្រូវបានរលាយបាត់អស់រលីង ក្នុងរវាងត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះ។ (ស្តាប់ទៅស្រដៀងនឹងរឿងឥឡូវនេះដែរទេ?) ទោះបីយ៉ាងណាក៏ដោយ អ្វីដែលពួកគេមិនដឹង ហើយមិនអាចមើលឃើញ គឺថា ព្រះនៅតែកំពុងធ្វើការយ៉ាងសកម្ម នៅក្នុងផែនការ ដើម្បីនាំមកនូវសេចក្តីសង្គ្រោះ និងសេចក្តីសង្ឃឹម ទៅកាន់ពិភពលោកទាំងមូល តាមរយៈការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ។ តាមពិតពួកគេបានលិចលង់ ក្នុងសេចក្តីកើតទុក្ខមិនសុខចិត្តរបស់ពួកគេខ្លាំងពេក ទើបពួកគេមិនអាចទាំងទទួលស្គាល់ព្រះយេស៊ូវ នៅពេលដែលទ្រង់បានលេចមកឲ្យពួកគេឃើញ នៅតាមផ្លូវទៅឯអេម៉ូស។ លោកលូកាបញ្ជាក់ថា នៅពេលព្រះយេស៊ូវសួរពួកគេ ថាតើពួកគេកំពុងតែពិភាក្សាគ្នាអំពីអ្វី "ពួកគេក៏នៅស្ងៀម ហើយមានទឹកមុខព្រួយ" (លូកា ២៤:១៧)។

ស្ថិតក្នុងគ្រាដែលមានវិបត្តិ និងភាពមិនប្រាកដប្រជាបែបនេះ ចូរប្រយ័ត្ន"ការជាប់គាំង"នៅលើវិថីនៃជីវិតដោយមានតែទឹកមុខក្រញូវ ព្រោះនឹកស្មានថាគ្រប់យ៉ាងត្រូវបាត់បង់ទាំងនោះឡើយ។ នៅពេលដែលដំណើរជីវិត ហាក់ដូចជាមិនសមហេតុផលសម្រាប់អ្នក ហើយអ្នកមិនអាចនឹកស្មានដល់ ថាតើហេតុអ្វីបានជាព្រះទ្រង់អាចជាផ្នែកមួយ នៃ

ការដែលកំពុងកើតឡើងដូច្នេះ ចូរចងចាំពីភាពមានដែនកំណត់ នៃសមត្ថភាពរបស់ ក្នុងការយល់ដឹងដល់ផ្លូវរបស់ព្រះ។ ព្រះទ្រង់អាចកំពុងតែធ្វើអ្វីមួយ ដែលអ្នកនឹកស្មានមិនដល់ កុំថាឡើយដល់ទៅអាចយល់ដល់ទៀតនោះ។

ខ្ញុំមិនមែនកំពុងនិយាយថា ព្រះទ្រង់ជាអ្នកបណ្ដាលឲ្យកើតជំងឺកូវីឌ១៩ ឬក៏ថា គ្រប់យ៉ាងនឹងត្រឡប់ទៅជាគ្មានបញ្ហាសម្រាប់មនុស្សគ្រប់គ្នាទេ។ វាមិនមែនអញ្ចឹងទេ។ ប៉ុន្តែ រឿងនេះរំឭកខ្ញុំពីអ្វីដែលលោកអេសាយបានប្រាប់យើង។ ផ្លូវរបស់ព្រះ មិនដូចជាផ្លូវរបស់យើងទេ។ ព្រះតែងតែធ្វើឲ្យយើងភ្ញាក់ផ្អើល។ម្ដងហើយម្ដងទៀត នៅក្នុងព្រះគម្ពីរ យើងអានឃើញថា ព្រះអង្គតែងតែនៅធ្វើការជានិច្ច ទោះស្ថិតក្នុងស្ថានភាពដែលហាក់ដូចជាអស់សង្ឃឹម ដើម្បីនាំមកនូវការល្អចេញពីការអាក្រក់ ការខាតបង់ មហន្តរាយ និងការឈឺចាប់។ រឿងរ៉ាវរបស់ពួកសិស្សពីរនាក់ដែលកំពុងកំសត់ នៅតាមផ្លូវទៅអេម៉ូស ដែលមិនអាចឃើញថា អ្នកដែលកំពុងឈរនៅចំពោះមុខពួកគេ គឺជាព្រះគ្រីស្ទដែលរស់ឡើងវិញ រំឭកយើងថា យើងទាំងអស់គ្នាសុទ្ធតែត្រូវការព្រះយេស៊ូវ ឲ្យបើកភ្នែករបស់យើង។ អ្វីដែលយើងត្រូវធ្វើ គឺយើងត្រូវសម្លឹងរកមើលព្រះគ្រីស្ទ ទោះស្ថិតនៅក្នុងពេលមានវិបត្តិ នៅទីកន្លែង និងតាមរបៀប ដែលយើងមិនរំពឹងថាទ្រង់នៅទីនោះ។

### *មេរៀនសម្រាប់ការអនុវត្តខាងវិញ្ញាណ*

តាមសម្រួលចុះ ចូរអធិស្ឋានសម្រាប់គ្រប់ទាំងសេចក្ដីត្រូវការ និងក្ដីបារម្ភនៅក្នុងចិត្តរបស់អ្នក ព្រោះយើងក៏មិនដឹងដែរថា ពេលណាដែលព្រះអាចជ្រើសរើសប្រាស់សេចក្ដីអធិស្ឋានដ៏ស្មោះត្រង់របស់យើង ដើម្បីនាំមកនូវការប្រោសឲ្យជា ការប្រោសឲ្យរួច ការផ្គត់ផ្គង់ ឬជំនួយដែលពិតជាត្រូវការបំផុត។ ប៉ុន្តែ ប្រសិនបើអ្នកអធិស្ឋានរបស់អ្នក មិនទទួលបានចម្លើយ តាមអ្វីដែលរំពឹងចង់បានទេ សូមកុំបាក់ទឹកចិត្តឲ្យសោះ។ សូមកុំឈប់ឈោងចាប់តាមព្រះ។ ទូលសូមព្រះយេស៊ូវគ្រីស្ទ ឲ្យបើកភ្នែករបស់អ្នក ឲ្យឃើញអ្វីដែលអ្នកមិនអាចឃើញដោយខ្លួនឯង ហើយទូលសូមព្រះវិញ្ញាណបរិសុទ្ធឲ្យពង្រឹងជំនឿរបស់អ្នក ហើយប្រើអ្នកសម្រាប់ការល្អ ក្នុងខណៈពេលនៃវិបត្តិបច្ចុប្បន្ននេះ។ ហើយ ទោះបីមានអ្វីកើតឡើងក៏ដោយ កុំភ្លេចស្វែងរកអ្វីដែលអ្នកដឹងថា ព្រះបានប្រទានឲ្យអ្នក។ ចូរប្រែចិត្តពីអំពើបាបរបស់អ្នក លះចោលសេចក្ដីជំពាក់ចិត្តទាំងឡាយណា ដែលមិនអាចធ្វើឲ្យអ្នកស្កប់ចិត្ត ឬធ្វើឲ្យអ្នកបែកអារម្មណ៍ចេញពីបំណងព្រះហឫទ័យសម្រាប់ជីវិតរបស់អ្នក។ ចូរស្វែងរកព្រះគុណ សេចក្ដីមេត្តាករុណានៃព្រះ និងអាហារខាងវិញ្ញាណ ដែលប្រាក់មិនអាចទិញបាន។ ព្រះជាម្ចាស់ដ៏ពេញដោយសេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណា ទ្រង់មានព្រះបន្ទូលថា "ចូរឱន ត្រចៀក ហើយមកឯអញ ចូរស្ដាប់ចុះ នោះព្រលឹងឯងនឹងបានរស់នៅ" (អេសាយ ៥៥:៣)។

ចំណាំ៖ សំណេរតែងសេចក្ដី នៅក្នុងកម្រងអត្ថបទនេះ គឺជាការពន្យល់បន្ថែម នៃការផ្ដល់អនុសាស្រ្តសម្រាប់ការអនុវត្តដែលបានផ្ដល់ជូននៅក្នុង ជំពូក ទី៨ "ការទុកចិត្តព្រះ" ក្នុងសៀវភៅដែលមានចំណងជើងថា *The Spirit-Led Leader: Nine Leadership Practices and Soul Principles* (Herndon, VA: Alban Institute, 2005), ទំព័រ 184-190។